ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៧
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩
សាលដីកា
លេខ: ០៦ (I)
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

# សាលដីកា
## នាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម`

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រមរបាយការណ៍

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

នៅលើបណ្តឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ផ្ទង់ ជាមេធាវីការពារ /សិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ពេជ មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៤សស.ក្រVII(ផ) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមាន៖

### ជនជាប់ចោទ៖

១.ឈ្មោះ [redacted] ខុច ភេទប្រុស អាយុ៦៤ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត នៅភូមិព្រៃសំណាងលើ ឃុំខ្លាយខាងជើង ស្រុកជងទង់ ខេត្តកំពត មានទីលំនៅបច្ចុប្បន្ន [redacted]

Scanned with CamScanner

[redacted] ខេត្តកំពត ប្រពន្ធឈ្មោះ [redacted] មានកូន ០៥នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុន "មាន" (ធ្លាប់ជាប់ពន្ធនាគារចំនួន ០៣ខែ)។

២.ឈ្មោះ [redacted] សើ ភេទប្រុស [redacted] ខេត្តកំពត។ (គេចខ្លួន)

៣.ឈ្មោះ [redacted] ចំរើន អតីតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិលេខរៀងទី៣ ខេត្តកំពត សព្វថ្ងៃរស់នៅរាជធានីភ្នំពេញ។ (គេចខ្លួន)

៤.ឈ្មោះ [redacted] ពេជ (សាទុក្ខ) ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)

មានមេធាវីការពារសិទ្ធិ លោក [redacted] ផ្លូវី

ត្រូវបានតុលាការដាក់ក្រោមការពិនិត្យពីបទៈ មិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ (ប្រឆាំងសាលដីការបស់តុលាការកំពូល), ប្រមូលផ្តុំញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅភូមិព្រៃសំណាងលើ ឃុំខ្លាយខាងជើង ស្រុកដងទង់ ខេត្តកំពត កាលពីអំឡុងខែមេសា, ឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៥២៣, ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ**

ឈ្មោះ [redacted] ចំរើន ជាអតីតតំណាងរាស្ត្រលេខរៀងទី៣ មណ្ឌលខេត្តកំពត បានទំនាក់ទំនងជាមួយឈ្មោះ [redacted] ខុច ភេទប្រុស អាយុ៦៩ឆ្នាំ ជាអតីតប្រធានប្រតិបត្តិ និងជាក្រុមប្រឹក្សាគណបក្សសង្គ្រោះជាតិស្រុកដងទុង ខេត្តកំពត តាមរយៈឆាតតាម Facebook ឬតាមឆាត ដោយបានប្រើឈ្មោះ [redacted] ខុច តាមដានសភាពការណ៍ផ្សេងៗដូចជា សកម្មភាពធ្វើបាតុកម្មរបស់លោក សម រង្ស៊ី ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចអាមេរិក មកលើប្រទេសកម្ពុជា ជាដើម។

លុះដល់ថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ចំរើន បានតេតាមឆាត បានប្រើឱ្យឈ្មោះ [redacted] ខុច ជ្រើសរើសមនុស្ស ក្នុងនោះរួមមាន អ្នកហ៊ានគាំទ្រចំនួន ០១នាក់ និងអ្នកខ្វះថវិកា ចំនួន១នាក់ ដើម្បីធ្វើការនេះ ឈ្មោះ [redacted] ខុច បានទទួលប្រាក់ពីឈ្មោះ [redacted] ចំរើន ចំនួន២០០$ តាមរយៈវេតាមវីង ។ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ចំរើន បានឆាតរូបបញ្ជីសមាជិកអ្នកគាំទ្ររបស់ខាងស្រុកឈូក ដែលមានឈ្មោះ [redacted] ពេជ ចុះហត្ថលេខា និងជាតំណាងស្រុកឈូក របស់គណបក្សសង្គ្រោះជាតិ ឲ្យយកតាមគម្រូបញ្ជីរបស់ខាងស្រុកឈូកនេះ។

ក្នុងទំនាក់ទំនងការងារខាងលើ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ [redacted] ខុច បានទាក់ទងគូកនឈ្មោះ [redacted] សើ នៅផ្ទះរបស់ឈ្មោះ [redacted] អ៊ិន ស្ថិតនៅភូមិអូរឬស្សី ឃុំស្រែជាខាងត្បូង ស្រុកដងទុង ខេត្តកំពត ក្នុងគោលបំណងដើម្បីរៀបចំចាត់តាំងប្រមូល ដើម្បីរៀបចំធ្វើសកម្មភាព ។

Scanned with CamScanner

នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ខុច ដោយបានដកហូតទូរសម្ភារៈវត្ថុតាង គឺកាបូបពណ៌ខ្មៅ មានសម្ភារៈរួមមានៈ

-របាយការណ៍ជួយឧបត្ថមប្រាក់គណបក្សសង្គ្រោះជាតិចំនួន ០១សន្លឹក

-សៀវភៅបោះពុម្ពសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពត ចំនួន ០១។

-ទូរស័ព្ទចំនួន ០២គ្រឿង ម៉ាកណូគាពណ៌ខ្មៅចំនួន ០១ ស៊ីមពីរ មានលេខ ០៦៦ ៨៥ ២៩ ៨៣, លេខ ០៩៣ ៣៩ ១៨ ៣៩, ម៉ាកសាំសុងពណ៌ខ្មៅ ០១គ្រឿង ប្រើស៊ីមមួយ លេខ ០៩២ ៨៥ ២៩ ៨៣។

ក្រោយការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ខុច បានឆ្លើយសារភាពថា នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ចំរើន ពិតជាបានតេតាមឆាតមកឱ្យខ្លួនជ្រើសរើសមនុស្ស ក្នុងនោះអ្នកហ៊ានគាំទ្រ ០៣ នាក់, អ្នកស្ទាក់ស្ទើចំនួន ០១នាក់ និងអ្នកខ្វះថវិការចំនួន ០១នាក់ ។ ដើម្បីធ្វើការនេះ ខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] ចំរើន ចំនួន២០០$ តាមរយៈវេតាមវីង។ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ ដាង ចំរើន បានឆាតរូបបញ្ជីសមាជិកអ្នកគាំទ្ររបស់ខាងស្រុកឈូក ដែលមានឈ្មោះ [redacted] ពេជ ចុះហត្ថលេខា និងជា តំណាងស្រុកឈូក របស់គណបក្សសង្គ្រោះជាតិ ឱ្យយកតាមគម្រូបញ្ជីរបស់ខាងស្រុកឈូកនេះ។ ប៉ុន្តែឈ្មោះ [redacted] ខុច បានឆ្លើយគេចវេសថា នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ខ្លួនបានទៅជួបឈ្មោះ [redacted] សើ នៅផ្ទះរបស់ឈ្មោះ [redacted] អ៊ីន ស្ថិតនៅភូមិអូឬស្សី ឃុំស្រែខាងត្បូង ស្រុកដងទង់ ខេត្តកំពត ថាខ្លួនបានជួបឈ្មោះ [redacted] សើ ជជែកគ្នាលេងធម្មតា ពុំបាននិយាយរឿងការងារអ្វីទេ។ ចំពោះគោលបំណងរបស់ឈ្មោះ [redacted] ចំរើន ឱ្យខ្លួនរើសយកមនុស្សទាំងនេះទៅធ្វើអ្វីក៏ខ្លួនពុំបានដឹងដែរ។ ឈ្មោះ [redacted] ចំរើន ពុំទាន់បានតែងតាំងខ្លួនជាអ្វីនោះទេ ប៉ុន្តែពីមុនមក ខ្លួនជាប្រធានប្រតិបត្តិស្រុកដងទង់ របស់គណបក្សសង្គ្រោះជាតិ។ក្រោយសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] សើ, ឈ្មោះ [redacted] ពេជ និងឈ្មោះ [redacted] ចំរើន បានគេចខ្លួនបាត់ ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំលេខ ៧៥៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-មិនអនុញ្ញាតឱ្យឈ្មោះ [redacted] ពេជ ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន នៅក្រៅឃុំ។

ដែលត្រូវចោទប្រកាន់ពីបទ មិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ (ប្រឆាំងសាលដីការបស់តុលាការកំពូល), ប្រមូលផ្តុំញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅភូមិព្រៃសំណាងលើ ឃុំខ្លាយខាងជើង ស្រុកដងទង់ ខេត្តកំពត កាលពីអំឡុងខែមេសា, ឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៥២៣, ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

Scanned with CamScanner

២-បង្គាប់ឲ្យក្រឡាបញ្ជី ជូនពត៌មានឲ្យជនត្រូវចោទឈ្មោះ [redacted]ពេជ ដើម្បីជ្រាប ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ជូងី មេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ពេជ ត្រង់ចំណុចដីកាសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៥៤ សស.ក្រVII(ធ) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២ ខែកញ្ញា ឆ្នាំ២០១៩ របស់មេធាវី [redacted] ជូងី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះសីលធម៌គតិច្បាប់ ។

២-តម្កល់ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំលេខ ៧៥៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត ទុកជាបានការដដែល ។

៣-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ របស់សាលាដំបូងទុកជាបានការនោះ គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ។

-ប៉ុន្តែដោយផ្អែកតាមស្ថានភាពជាក់ស្តែង ជនត្រូវចោទត្រូវបានសាលាដំបូងដោះលែងឲ្យនៅក្រៅឃុំរួចហើយ ។

**<u>ហេតុដូច្នេះ</u>**

**<u>តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាជំនុំជំរះសម្រេច៖</u>**

-សុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned with CamScanner

## សំអាងហេតុ

### តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] ជូងី ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] ពេជ ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមលិខិតជូនដំណឹងចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ របស់លោក [redacted] ជូងី ជាមេធាវីការពារក្តីឱ្យជនត្រូវចោទឈ្មោះ [redacted] ពេជ មកតុលាការកំពូលថា ជនត្រូវចោទឈ្មោះ [redacted] ពេជ ត្រូវបានសាលា ដំបូងខេត្តកំពតដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ រួចហើយ ដូច្នេះ បណ្តឹងសាទុក្ខរបស់ជនត្រូវចោទដែលធ្វើឡើងតាមរយៈមេធាវី [redacted] ជូងី ពុំមានភាពចាំបាច់អាចឱ្យតុលាការកំពូល ពិចារណាលើអង្គច្បាប់ទៀតទេ។

៣-យល់ឃើញថា សាលដីកាសភាស៊ើបសួរលេខ ៥៤ សស.ក្រ.VII(ជ) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះខុសនឹងគតិច្បាប់។

## ហេតុដូច្នេះ

### តុលាការសម្រេចសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] ជូងី ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] ពេជ ក្នុងការប្តឹងសាទុក្ខ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៥៤ សស.ក្រ.VII (ជ) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ។

៣-ដោះលែងជនត្រូវចោទឈ្មោះ [redacted] ពេជ ឱ្យនៅក្រៅការឃុំខ្លួន ប្រសិនបើជននេះមិនត្រូវបានជាប់ឃុំខ្លួនពីបទល្មើសផ្សេងទៀតនោះទេ។

Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០។

Scanned with CamScanner